ឆ្នាំទី១៦ លេខ ៣៥ សប្តាហ៍ទី ២ ថ្ងៃទី ១២ ខែ ឧសភា ឆ្នាំ ២០១៦ រាជកិច្ច ទំព័រ ៤១១១

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខ:...៤៥...សសរ

# សេចក្តីសម្រេច
## ស្តីពី
## ការបង្កើតគណៈកម្មការរៀបចំពិធីដង្ហែព្រះបរមសារីរិកធាតុព្រះសម្មាសម្ពុទ្ធជាអម្ចាស់ ពីព្រះបរមរាជវាំងទៅតម្កល់ទុកនៅព្រះមហាសក្យមុនីចេតិយ ភ្នំអដ្ឋរស្សឡើងវិញ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៤១៦/៣៦៨ ចុះថ្ងៃទី០៤ ខែមេសា ឆ្នាំ២០១៦ ស្តីពីការកែសម្រួល និងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៩ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងធម្មការនិងសាសនា
- បានឃើញអនុក្រឹត្យលេខ ១៥៤ អនក្រ.បក ចុះថ្ងៃទី១១ ខែកក្កដា ឆ្នាំ២០១១ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងធម្មការនិងសាសនា
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងធម្មការនិងសាសនា

## សម្រេច

**ប្រការ ១.-**

ត្រូវបានបង្កើតគណៈកម្មការរៀបចំពិធីដង្ហែព្រះបរមសារីរិកធាតុ ព្រះសម្មាសម្ពុទ្ធជាអម្ចាស់ពីព្រះបរមរាជវាំងទៅតម្កល់ទុកនៅព្រះមហាសក្យមុនីចេតិយ ភ្នំអដ្ឋរស្សឡើងវិញ ដែលនឹងប្រព្រឹត្តទៅនៅថ្ងៃសុក្រ ១៥កើត ខែពិសាខ ឆ្នាំវក អដ្ឋស័ក ពុទ្ធសករាជ ២៥៦០ ត្រូវនឹងថ្ងៃទី២០ ខែឧសភា ឆ្នាំ២០១៦ ដែលមានសមាសភាពដូចខាងក្រោមៈ

១-សម្តេចព្រះអគ្គមហាសង្ឃរាជាធិបតី **នន្ទ ង៉ែត** សម្តេចព្រះមហាសង្ឃរាជនៃព្រះរាជាណាចក្រកម្ពុជា ព្រះអធិបតី

២-សម្តេចព្រះអភិសិរីសុគន្ធាមហាសង្ឃរាជាធិបតី **បួរ គ្រី** សម្តេចព្រះមហាសង្ឃរាជនៃគណៈធម្មយុត្តិកនិកាយនៃព្រះរាជាណាចក្រកម្ពុជា ព្រះអធិបតី

www.pheakdeylaw.com

៣-សម្តេចព្រះមហាសុមេធាធិបតី **នន្ទ ង៉ែត** សម្តេចព្រះសង្ឃនាយកនៃព្រះរាជាណាចក្រកម្ពុជា ព្រះអធិបតី
៤-ឯកឧត្តម **ហ៊ឹម ឆែម** ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងធម្មការនិងសាសនា សហប្រធាន
៥-លោកជំទាវ **ភឿង សកុណា** រដ្ឋមន្ត្រីក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ សហប្រធាន
៦-សម្តេចព្រះពោធិវង្ស **អំ លឹមហេង** សម្តេចព្រះសង្ឃនាយករងនៃព្រះរាជាណាចក្រកម្ពុជា អនុប្រធាន
៧-ឯកឧត្តម **ខៀវ កាញារីទ្ធ** រដ្ឋមន្ត្រីក្រសួងព័ត៌មាន អនុប្រធាន
៨-ឯកឧត្តម **ឆ្លោក ផន** រដ្ឋលេខាធិការក្រសួងធម្មការនិងសាសនា អនុប្រធានអចិន្ត្រៃយ៍
៩-ឯកឧត្តម **នរៈ រតនៈវឌ្ឍនោ** រដ្ឋលេខាធិការក្រសួងធម្មការនិងសាសនា សមាជិក
១០-ឯកឧត្តម **យូ ស៊ុនឡុង** រដ្ឋលេខាធិការក្រសួងមុខងារសាធារណៈ សមាជិក
១១-ឯកឧត្តម **វង្សី វិស្សុត** រដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ សមាជិក
១២-ឯកឧត្តម **ឃឹម សារិទ្ធ** រដ្ឋលេខាធិការក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ សមាជិក
១៣-ឯកឧត្តម **ឈិន កេតនា** អនុប្រធានអចិន្ត្រៃយ៍ និងជាអគ្គលេខាធិការគណៈកម្មាធិការជាតិរៀបចំបុណ្យជាតិ-អន្តរជាតិ សមាជិក
១៤-ឯកឧត្តម **សុខុម ភត្តវ័នមុនី** រដ្ឋលេខាធិការក្រសួងសាធារណការ និងដឹកជញ្ជូន សមាជិក
១៥-ឯកឧត្តម នាយឧត្តមសេនីយ៍ **នេត សាវឿន** អគ្គស្នងការនៃអគ្គស្នងការដ្ឋាននគរបាលជាតិ សមាជិក
១៦-ឯកឧត្តម នាយឧត្តមសេនីយ៍ **សៅ សុខា** អគ្គមេបញ្ជាការរងនៃអគ្គបញ្ជាការដ្ឋានកងយោធពលខេមរភូមិន្ទ និងជាមេបញ្ជាការកងរាជអាវុធហត្ថលើផ្ទៃប្រទេស សមាជិក
១៧-ឯកឧត្តម **កែវ រតនៈ** ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាអគ្គនាយកអគ្គិសនីកម្ពុជា សមាជិក
១៨-ឯកឧត្តម **ឌួន លឹមហេង** អនុរដ្ឋលេខាធិការទីស្តីការគណៈរដ្ឋមន្ត្រី សមាជិក
១៩-ឯកឧត្តម **ញ៉ែម ម៉ាលី** អនុរដ្ឋលេខាធិការក្រសួងធម្មការនិងសាសនា សមាជិក
២០- ឯកឧត្តម **ប៉ា សុជាតិវង្ស** អភិបាលនៃគណៈអភិបាលរាជធានីភ្នំពេញ សមាជិក
២១-ឯកឧត្តម **ម៉ៅ ភិរុណ** អភិបាលនៃគណៈអភិបាលខេត្តកណ្តាល សមាជិក
២២-ឯកឧត្តម **លន់ លឹមថៃ** អភិបាលនៃគណៈអភិបាលខេត្តកំពង់ចាម សមាជិក
២៣-ឯកឧត្តម **អ៊ុី សំណាង** អភិបាលនៃគណៈអភិបាលខេត្តកំពង់ស្ពឺ សមាជិក
២៤-ឯកឧត្តម **ឈួរ ច័ន្ទឿន** អភិបាលនៃគណៈអភិបាលខេត្តកំពង់ឆ្នាំង សមាជិក។

**ប្រការ ២.-**

គណៈកម្មការនេះ មានភារកិច្ច ដូចតទៅ ៖

- សហការជាមួយក្រសួង-ស្ថាប័ន រាជធានី-ខេត្តពាក់ព័ន្ធ និងគណៈសង្ឃនាយក ដើម្បីរៀបចំពិធីខាងលើនេះឱ្យបានជោគជ័យ។
- ត្រួតពិនិត្យនិងលើកសំណើដោះស្រាយរាល់បញ្ហានានា ការពារសន្តិសុខ សណ្តាប់ធ្នាប់ក្នុងពិធីឱ្យបានល្អប្រសើរ។
- លើកគម្រោងចំណូល-ចំណាយ អំពាវនាវសប្បុរសជនឱ្យជួយឧបត្ថម្ភដើម្បីបម្រើឱ្យពិធីទាំងមូល។

- ត្រៀមលក្ខណៈផ្សព្វផ្សាយឱ្យបានទូលំទូលាយតាមគ្រប់មធ្យោបាយ និងគ្រប់រូបភាព ដោយមានបដារពាក្យស្លោកធំៗ នៅតាមទីប្រជុំជន រាជធានី-ខេត្ត ក្នុងទូទាំងព្រះរាជាណាចក្រកម្ពុជា តាមបណ្តាស្ថានីយ៍ទូរទស្សន៍ និងតាមបណ្តាញព័ត៌មានសង្គមនានា ដោយដាក់រូបភាពពុទ្ធប្រវត្តិ។
- បំពេញភារកិច្ចដាក់ស្តែងផ្សេងទៀត តាមការចាំបាច់សម្រាប់បម្រើឱ្យពិធីទាំងមូល។

**ប្រការ ៣.-**

គណៈកម្មការនេះ អាចបង្កើតអនុគណៈកម្មការ និងក្រុមការងារជំនាញបន្ថែមទៀតជាជំនួយការតាមតម្រូវការចាំបាច់។

**ប្រការ ៤.-**

សមាសភាពនៃគណៈកម្មការនេះ ត្រូវចូលរួមប្រជុំតាមការអញ្ជើញរបស់ប្រធាន។ ក្នុងករណីប្រធានអវត្តមាន អនុប្រធាន មានសិទ្ធិពេញលេញ ក្នុងការដឹកនាំការងារ តាមការប្រគល់សិទ្ធិរបស់ប្រធាន ។

**ប្រការ ៥.-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងសេចក្តីសម្រេចនេះ ត្រូវទុកជានិរាករណ៍។

**ប្រការ ៦.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងធម្មការនិងសាសនា រដ្ឋមន្ត្រីគ្រប់ក្រសួងនិងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ និងសាមីខ្លួន ត្រូវទទួលបន្ទុកអនុវត្តសេចក្តីសម្រេចនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

រាជធានីភ្នំពេញ ថ្ងៃទី ០៩ ខែ ឧសភា ឆ្នាំ២០១៦

នាយករដ្ឋមន្ត្រី

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល:**
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- គណៈកម្មាធិការជាតិរៀបចំបុណ្យជាតិ-អន្តរជាតិ
- ខុទ្ទកាល័យសម្តេចតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវឧបនាយករដ្ឋមន្ត្រី
- ដូចប្រការ៦
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ